# ជំងឺក្អកមាន់

Public Health
Seattle & King County

## តើអ្វីទៅជាជំងឺក្អកមាន់?



ជំងឺក្អកមាន់បណ្តាលមកពីមេរោគបាក់តេរីដែលសាយភាយនៅតាមខ្យល់។ សញ្ញាដំបូងៗនៃជំងឺក្អកមាន់អាចចាប់ផ្តើមឡើងដូចជាផ្តាសាយធម្មតា។ ក្រោយមក វាក្លាយជាក្អកឥតឈប់ឈរ ក្អួត ឬពិបាកដកដង្ហើម។

## តើកំពុងមានអ្វីកើតឡើងនៅក្នុងតំបន់ King County?



ករណីកើតជំងឺក្អកមាន់កំពុងតែកើនឡើងនៅតំបន់ King County និងទូទាំងសហរដ្ឋអាមេរិក។ មនុស្សជាច្រើនដែលកើតជំងឺនេះគឺជាកុមារ រួមទាំងទារកផងដែរ។ ពួកគេមួយចំនួនត្រូវសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។

## តើខ្ញុំអាចធ្វើអ្វីបាន?

ការចាក់វ៉ាក់សាំងគឺជាវិធីល្អបំផុត ដើម្បីបង្ការជំងឺក្អកមាន់។ វាសំខាន់ជាពិសេសសម្រាប់ទារក និងមនុស្សមានផ្ទៃពោះ ដោយសារទារកអាចនឹងឈឺធ្ងន់។ ថ្នាំវ៉ាក់សាំងសម្រាប់ជំងឺក្អកមាន់មានសុវត្ថិភាពសម្រាប់កុមារ និងមនុស្សពេញវ័យ រួមទាំងមនុស្សមានផ្ទៃពោះ។

ថ្នាំវ៉ាក់សាំងក៏ដូចជាឱសថផ្សេងទៀតដែរ វាអាចមានផលប៉ះពាល់ដល់សុខភាព។ ផលប៉ះពាល់ជាទូទៅបំផុតមានកម្រិតស្រាល និងបាត់ទៅវិញដោយខ្លួនឯង។ សូមមើលតារាងខាងក្រោមដើម្បីមើលអោយបានដឹងថា តើថ្នាំវ៉ាក់សាំងណាមួយស័ក្តិសមសម្រាប់អ្នក។






| ទារក និងក្មេងតូចៗ | ក្មេងជិតវ័យជំទង់ | មនុស្សមានផ្ទៃពោះ | មនុស្សពេញវ័យ 19+ ឆ្នាំឡើងទៅ |
|---|---|---|---|
| Diphtheria, Tetanus, Pertussis (DTaP, ខាន់ស្លាក់, តេតាណូស, ក្អកមាន់) | Tetanus, Diphtheria, Pertussis (Tdap, តេតាណូស, ខាន់ស្លាក់, ក្អកមាន់) | Tetanus, Diphtheria, Pertussis (Tdap, តេតាណូស, ខាន់ស្លាក់, ក្អកមាន់) | Tetanus, Diphtheria, Pertussis (Tdap, តេតាណូស, ខាន់ស្លាក់, ក្អកមាន់) |
| 2, 4 និង 6 ខែ<br>15-18 ខែ<br>4-6 ឆ្នាំ | 11-12 ឆ្នាំ | ត្រីមាសទីបីពេលមានផ្ទៃពោះមួយលើកៗ | ពេលណាក៏បានសម្រាប់មនុស្សមិនធ្លាប់ចាក់វ៉ាក់សាំងនេះ |

ត្រូវការគ្រូពេទ្យមែនទេ? សូមទាក់ទងទៅ Community Health Access Program (កម្មវិធីផ្តល់លទ្ធភាពផ្នែកសុខភាពសហគមន៍) ដោយហៅទូរសព្ទទៅលេខ 1-800-756-5437 ឬផ្ញើអ៊ីមែលទៅ CHAP@kingcounty.gov។

ស្វែងយល់បន្ថែមអំពីជំងឺក្អកមាន់៖
bit.ly/kcpertussis